**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**

**និងប្រព័ន្ធយុត្តិធម៌**

**អគ្គលេខាធិការដ្ឋាន**

# របាយការណ៍ ស្តីពី សិក្ខាសាលាស្តីពីការផ្លាស់ប្តូរយោបល់រវាងភ្នាក់ងារអនុវត្ត និងសង្គមស៊ីវិល ទាក់ទងនិងការអនុវត្តន៍កម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការនៅខេត្តបន្ទាយមានជ័យ

ឆ្នាំពីរពាន់ប្រាំបួន ខែកញ្ញា ថ្ងៃទីដប់ពីរ និងដប់បី វេលាម៉ោងប្រាំបួនព្រឹក នៅសណ្ឋាគារជំនោរសែសិន ខេត្តបន្ទាយមានជ័យ មានរៀបចំសិក្ខាសាលាមួយក្រោមអធិបតីភាព ឯកឧត្តម **ស្នួង លាងហៃ** អគ្គលេខាធិការរង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានការចូលរួមពីឯកឧត្តម **អ៊ឹម ធន់សុផល** អភិបាលរងខេត្តបន្ទាយមានជ័យ ដើម្បីពិភាក្សាផ្លាស់ ប្តូរយោបល់រវាងភ្នាក់ងារអ្នកអនុវត្ត និងសង្គមស៊ីវិលលើបញ្ហាកំណែទម្រង់ច្បាប់ និងតុលាការ នៅខេត្តបន្ទាយមានជ័យ។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់មកជាមួយ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម **អ៊ឹម ធន់សុផល** អភិបាលរងខេត្តបន្ទាយមានជ័យបានស្វាគមន៍ចំពោះ គណៈអធិបតី និងថ្លែងអំណរគុណឯកឧត្តមអគ្គលេខាធិការរង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ដែលបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងពិភាក្សាផ្លាស់ប្តូរយោបល់លើកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការជាមួយភ្នាក់ងារអនុវត្ត និងសង្គមស៊ីវិលដើម្បីផ្តល់នូវព័ត៌មាន និងចែករំលែកនូវបទពិសោធន៍ផ្សេងៗ ដល់មន្ត្រីរបស់ស្ថាប័នជំនាញនានានៅតាមខេត្តឱ្យមានការយល់ដឹងកាន់តែប្រសើរឡើងថែមទៀតអំពីការកែទម្រង់ច្បាប់ និងតុលាការ។ ឯកឧត្តមបានស្នើឱ្យអង្គសិក្ខាសាលាពិភាក្សាផ្លាស់ប្តូរយោបល់ឱ្យបានផុសផុលអំពីបញ្ហាកំណែទម្រង់ច្បាប់ និងតុលាការហើយសង្ឃឹមថាសហការីមកពីមន្ទីរ-ស្ថាប័នជំនាញផ្សេងៗជុំវិញ ខេត្តនឹងចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចពិភាក្សាផ្លាស់ប្តូរយោបល់នេះ នឹងប្រើប្រាស់ឱកាសនេះឱ្យបានល្អដើម្បីបន្ថែមនូវការយល់ ដឹងឱ្យកាន់តែប្រសើរថែមទៀតលើវិស័យកំណែទម្រង់ច្បាប់ និងតុលាការ។ ជាមួយគ្នានេះដែរឯកឧត្តមបានបញ្ជាក់ថា ខេត្តបន្ទាយមានជ័យមានការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការអនុវត្តន៍សកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការ និងបន្តនូវការគាំទ្រឱ្យបានខ្លាំងក្លាដើម្បីអនុវត្តការងារនេះ ហើយសង្ឃឹមថាសកម្មភាពកំណែទម្រង់ផ្សេងៗរបស់ខេត្តបន្ទាយមានជ័យ នឹងអាចច្របាច់បញ្ចូលទៅក្នុងផែនការសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការរបស់រាជរដ្ឋាភិបាលទាំងស្រុង ដើម្បីជួយជំរុញដល់ការអនុវត្តន៍យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការអោយកាន់តែប្រសើរថែមទៀត។

ឯកឧត្តម **សួង លាងហៃ** អគ្គលេខាធិការរងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បានលើកឡើងថា កំណែទម្រង់ច្បាប់ និងតុលាការជាសមាសធាតុសំខាន់មួយ នៃអភិបាលកិច្ចល្អដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលតាំងពីនីតិកាលទី៣ នៃរដ្ឋសភាមកម្លេះក្នុងការឆ្ពោះទៅរកការកាត់បន្ថយភាពក្រីក្រ។ ជាបន្ទាប់ឯកឧត្តមបានរំលឹកអំពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ដែលមានសមាសភាពចម្រុះមកពីអង្គការនីតិប្រតិបត្តិ និងតុលាការពីការកសាងឯកសារចក្ខុវិស័យ និងយុទ្ធសាស្ត្រសម្រាប់កំណែទម្រង់ច្បាប់ និងតុលាការដែលបានទទួលការអនុម័តនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៣ និងឯកសារស្តីពីកម្មវិធីសកម្មភាពអនុម័តនៅថ្ងៃទី២៩ ខែ មេសា ឆ្នាំ២០០៥ ដោយគណៈរដ្ឋមន្ត្រី។

លោក **ឃ្លោក ដារ៉ា** ប្រធានផ្នែកគម្រោងសិទ្ធិមនុស្ស នៃអគ្គលេខាធិការក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានធ្វើបទបង្ហាញការអនុវត្ត និងភាពជឿនលឿននៃការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយបញ្ចាំងស្លាយតាមឯកសារដែលបានចែកជូន។

លោក **អាំង មាលតី** ប្រធានសាលាដំបូងខេត្តបន្ទាយមានជ័យ បានឡើងធ្វើបទបង្ហាញអំពីដំណើរការផ្លូវច្បាប់នៅក្នុងរឿងរដ្ឋប្បវេណី និងរឿងព្រហ្មទណ្ឌ។ លោកបានបញ្ជាក់ថា ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមនីតិវិធីរដ្ឋប្បណីត្រូវបានប្រកាសឱ្យប្រើនៅក្នុងខែកក្កដា ឆ្នាំ២០០៩ និងក្រមព្រហ្មទណ្ឌត្រូវបានប្រកាសអោយប្រើនៅក្នុងខែសីហា ឆ្នាំ២០០៩ ដោយលោកបានបញ្ជាក់ថា ក្រមនីតិវិធីរដ្ឋប្បវេណីមានលក្ខណៈថ្មីខុសពីក្រមចាស់ និងត្រូវបានយកមកអនុវត្តផ្ទួនៗតែម្តង ដែលជាហេតុធ្វើអោយមានការពិបាកដល់មន្ត្រីអនុវត្តច្បាប់របស់យើង។ លោកបានបញ្ជាក់ថា មន្ត្រីរបស់យើងបានខិតខំរៀនសូត្រផងហើយក៏អនុវត្តផងដែរ។ បញ្ហាប្រឈមសម្រាប់តុលាការខេត្តបន្ទាយមានជ័យមានដូចជា៖

-កង្វះធនធានមនុស្ស និងសមត្ថភាពនៃការដឹកនាំការគ្រប់គ្រង

-ការខ្វះខាតក្នុងការបញ្ជូនពត៌មាន«ប្រព័ន្ធនៃការផ្តល់ព័ត៌មានរវាងពន្ធនាគារ និងចៅក្រម»។

ពាក់ព័ន្ធនឹងការរៀបចំរដ្ឋបាលតុលាការ មកទល់នឹងពេលនេះជិត១ឆ្នាំមកហើយ ដែលលោកបានរៀបចំរដ្ឋបាលតុលាការ សម្រាប់សាលាដំបូងខេត្តនេះដើម្បីអោយមានដំណើការល្អ ប៉ុន្តែការរៀបចំនេះពុំទាន់មានលក្ខណៈត្រូវត្រូវនៅឡើយ ហេតុនេះលោកក៏បានឆ្លៀតឱកាសនេះ ដើម្បីធ្វើការស្នើសុំលោក(Ben Schultz ) CCJAP III ជួយក្នុងរឿងរដ្ឋបាលតុលាការនេះ។ ម្យ៉ាងទៀតប្រជាពលរដ្ឋ នៅពុំទាន់បានយល់ពីច្បាប់ ឱ្យបានទូលំទូលាយឡើយ។

លោក **តន់ សីហៈតេជៈ** ព្រះរាជអាជ្ញារងខេត្ត បានធ្វើបទបង្ហាញពន្យល់ជូនដល់អង្គសិក្ខាសាលាពាក់ព័ន្ធនឹងតួនាទីរបស់មន្ត្រីនគរបាលយុត្តិធម៌ តួនាទីរបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ និងប្រភេទរឿងក្តីព្រហ្មទណ្ឌដែលត្រូវបញ្ជូនមកខាងអយ្យការ។ លោកក៏បានលើកឡើងនូវនីតិវិធីនៃឃុំខ្លួន នីតិវិធីនៃការពន្យារពេលនៃការឃុំខ្លួន បទល្មើសឧក្រិដ្ឋ បទល្មើសមជ្ឈឹម បទលហុ និងអំពីនីតិវិធីនៃការឃាត់ខ្លួន ដែលមានចែងក្នុងក្រមថ្មី។

សំណួរ ៖

លោក **ផាន់ តឹន** ប្រធានក្រុមប្រឹក្សាឃុំ គោកកបិន លោកបានលើកសំណួរសួរថា៖

១-ពាក់ព័ន្ធនឹងទិសដៅជាយុទ្ធសាស្ត្រទី៦ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ តើក្រុមប្រឹក្សាឃុំសង្កាត់មានសិទ្ធិត្រឹមណាក្នុងដំណោះស្រាយ?

២-ចំពោះបទរំលោភសេពសន្ថវៈ លោកបានលើកឧទាហរណ៍ថា មានករណីរំលោភសេពសន្ថវៈមួយហើយត្រូវបានសម្របសម្រួលត្រឹមថ្នាក់ឃុំ និងបានយល់ព្រមផ្តិតមេដៃ និងសំណងផ្សេងៗរួចរាល់ចប់សព្វគ្រប់ ប៉ុន្តែក្រោយមកភាគីរងគ្រោះក៏បានមកប្តឹងទៅតុលាការ ហើយតុលាការបានចេញដីកាចាប់តែម្តង ដោយលោកយល់ឃើញថា តុលាការមិនដែលបានចុះទៅអង្កេតអោយបានគ្រប់ជ្រុងជ្រោយដល់ទីលំនៅទេ។ លោកបានសួរបញ្ជាក់ថាតើបញ្ហាខាងលើនេះ ក្រុមប្រឹក្សាឃុំមានសិទ្ធិសម្រេចត្រឹមណាដែរ?

ឯកឧត្តមប្រធានអង្គសិក្ខាសាលាបានបំភ្លឺបញ្ជាក់ថា គម្រោងដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដែលអនុវត្តដោយក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ក្រោមជំនួយរបស់អង្គការ UNDPបានបង្កើតនូវមណ្ឌលសេវាកម្មយុត្តិធម៌មានថ្នាក់ស្រុកសាកល្បងនៅខេត្តកំពង់ស្ពឺចំនួនពីរស្រុក និងខេត្តកំពង់ឆ្នាំងចំនួនពីរស្រុកនៅក្នុងឆ្នាំ២០០៧ ហើយក្នុងឆ្នាំ២០០៩នេះ បានពង្រីកបន្ថែមទៅកាន់ខេត្តសៀមរាប បាត់ដំបង មណ្ឌលគិរី និងរតនៈគិរី សរុបចំនួន២០ស្រុក។ គម្រោងនេះមានទិសដៅដាក់បញ្ចូលការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅកម្ពុជា ហើយកំពុងតែដំណើរការទៅមុខតាមការគ្រោងទុក។ ប៉ុន្តែចំពោះសិទ្ធិអំណាចរបស់ឃុំសង្កាត់ក្នុងរឿងដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះ ច្បាប់ស្តីពីការគ្រប់គ្រងឃុំសង្កាត់មានកំណត់ខ្លះៗហើយដែរ។

លោក **អាំង មាលតី** បានបញ្ជាក់ថា ឃុំសង្កាត់មានធ្វើការសម្រួលសម្រួលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែលជាបទលហុមានលក្ខណៈតូចតាច ដូចជារឿងជំពាក់លុយកាក់តិចតួចជាដើម? ប៉ុន្តែចំពោះរឿងព្រហ្មទណ្ឌ បទល្មើសមជ្ឈឹមមិនអាចសម្រុះសម្រួលបានទេ។

ប្រធានមន្ទីរបរិស្ថានខេត្តបន្ទាយមានជ័យ លោកបានលើកឡើងពាក់ព័ន្ធនឹងបទបង្ហាញ របស់កំណែទម្រង់ច្បាប់ និងតុលាការ ហើយបានចោទសួរថា៖

១-តើយើងគួរពង្រីកយន្តការរបស់តុលាការ ឬកាត់បន្ថយជម្លោះរបស់ប្រជាពលរដ្ឋយ៉ាងដូចម្តេច?

២-ពាក់ព័ន្ធនឹងរឿងសិទ្ធិមនុស្ស ថាតើឱ្យតែមានការងារអ្វីត្រូវរត់រកអង្គការសិទ្ធិមនុស្សឬ?

៣-តើមានយន្តការអ្វីដើម្បីផ្សព្វផ្សាយច្បាប់អោយបានដល់ប្រជាពលរដ្ឋ? តើស្ថាប័ណាជាអ្នកទទួលខុសត្រូវ?

៤-ពាក់ព័ន្ធនិងបណ្ណ័មូលនិធិសមធម៌ ដែលមានបង្កើតនៅតាមបណ្តាខេត្តផ្សេងៗ តើគេអាចយកទៅប្រើប្រាស់ក្នុងស្ថាប័នតុលាការបានដែរឬទេ?

ឯកឧត្តមប្រធានអង្គសិក្ខាសាលាបានឆ្លើយចំពោះសំណួរទី១ថាក្នុងការពង្រឹងតុលាការយើងមានយុទ្ធសាស្ត្រ យើងមានផែនការ សកម្មភាពរបស់យើងសម្រាប់រយៈពេលយូរព្រោះថា ការកែទម្រង់ត្រូវការពេលវេលាហើយត្រូវធ្វើជារហូត។ នៅពេលណាសង្គមជាតិយើងវិវត្តទៅមុខរីកចម្រើនឡើង បញ្ហាថ្មីៗក៏កើតមានឡើងតម្រូវអោយមានដំណោះស្រាយថ្មីៗទៅតាមនោះមិនចេះឈប់។ ចំពោះសំណួរទី២ ឯកឧត្តមបានបំភ្លឺថាអគ្គលេខាធិការក្រុមប្រឹក្សា

កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌មានគម្រោងមានគម្រោង បង្កើតស្ថាប័នទទួលពាក្យបណ្តឹងប្រជាពលរដ្ឋថ្នាក់ជាតិ(Ombudsman) ដែលសព្វថ្ងៃកំពុងស្ថិតនៅក្នុងដំណាក់កាល នៃការសិក្សាស្រាវជ្រាវ រៀបចំរបាយការណ៍លើកសំណើជូនក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ពិនិត្យនឹងសម្រេច។

ចំពោះសំណួរទី៣ តើមានយន្តការអ្វី ដើម្បីផ្សព្វផ្សាយច្បាប់ឱ្យបានជ្រួតជ្រាបដល់ប្រជាពលរដ្ឋនោះ? ឯកឧត្តមបានបញ្ជាក់ថា វាអាស្រ័យលើបញ្ញាថវិកា និងធនធាន។ យើងមានស្ថាប័នថ្នាក់ជាតិមួយគឺ អគ្គនាយកដ្ឋានរាជកិច្ច ហើយក្រសួងស្ថាប័នផ្សេងៗទៀត ក៏មានភារកិច្ចទទួលខុសត្រូវផ្សព្វផ្សាយការបណ្តុះបណ្តាលច្បាប់ក្នុងនាមសមត្ថកិច្ចរៀងៗខ្លួនដែរ។

ចំពោះសំណួរទី៤ ដែលពាក់ព័ន្ធនិងប័ណ្ណមូលនិធិសមធម៌ ឯកឧត្តមក៏បានស្នើឱ្យខាងអាជ្ញាធរខេត្តធ្វើការស្រាយបំភ្លឺ។

លោកប្រធានសាលាដំបូងខេត្តបន្ទាយមានជ័យ បាននិយាយពីជំនួយសង្គ្រោះនៃបណ្តឹងតាមរយៈ "ប័ណ្ណមូលនិធិសមធម៌" ដែលត្រូវបានចេញដោយអង្គការ។ ចំពោះចៅក្រមដែលកាន់រឿងក្តីអ្នកដែលមានប័ណ្ណគាត់អាចមើលទៅលើប្រភេទរឿងក្តីថា តើអាចជួយបានដែរឬទេ ថាតើមានគោលការណ៍អ្វីខ្លះដែលអាចជួយគាត់បាន? ព្រោះថានៅពេលឈ្នះក្តី គាត់អាចបង់ពន្ធជូនរដ្ឋបាន។ ហេតុនេះនៅពេលសំណុំរឿងចូលដល់ចៅក្រមគួរពិនិត្យមើលថា តើអាចឈ្នះក្តីដែរឬអត់? បើសិនជារឿងនោះចៅក្រមមើលទៅឃើញថាមិនអាចឈ្នះបានទេ នោះចៅក្រមមិនអាចសង្គ្រោះលើរឿងក្តីនោះទេ ព្រោះថា បើចាញ់ក្តីទៅគ្មានអ្នកណាជាអ្នកធានាបង់ប្រាក់សាច់រឿងក្តី។

លោក **ស៊ុំ ចន្ធា** ជាអ្នកសម្របសម្រួលសមាគមន៍អាដហុក អង្គការ-សមាគមន៍មិនមែនរដ្ឋាភិបាលបំពេញការងារលើការឃ្លាំមើលការអនុវត្តច្បាប់ បានឡើងធ្វើបទបង្ហាញតំណាងអង្គការក្រៅរដ្ឋាភិបាល ខេត្តបន្ទាយមានជ័យ និងបានលើកឡើងនូវចំណុចចន្លោះប្រហោងមួយចំនួន របស់ភ្នាក់ងារអនុវត្តច្បាប់ក្នុងការបំពេញតួនាទីរបស់ខ្លួនកន្លងមក មិនទាន់បានត្រឹមត្រូវតាមនីតិវិធីច្បាប់នៅឡើយ ដូចជាការសាកសួរចម្លើយមានការវាយដំបង្ខំលើរាងកាយ ការឃាត់ខ្លួនលើសនីតិវិធី ការសម្របសម្រួលបទល្មើសព្រហ្មទណ្ឌពីអាជ្ញាធរសមត្ថកិច្ចបណ្តឹងព្រហ្មទណ្ឌមានការបង់ប្រាក់ពន្ធផ្សេងៗ និងប្រាក់ក្រៅពន្ធ បញ្ហាដីធ្លី។ល។

លោកឧត្តមសេនីយត្រី **ហ៊ុន ហ៊ាង** ស្នងការនគរបាលខេត្តបន្ទាយមានជ័យបានឡើងចាប់អារម្មណ៍មួយចំនួនពាក់ព័ន្ធក្នុងការអនុវត្តច្បាប់៖

លោកបានលើកឡើងថា មានអង្គការក្រៅរដ្ឋាភិបាលមួយចំនួន មានដំណើរការល្អក្នុងការតាមដានការអនុវត្តច្បាប់ក្នុងការជួយពង្រឹងការអនុវត្តច្បាប់បានល្អ ប៉ុន្តែមានអង្គការមួយចំនួនទៀតដែលបានជួយ "ប៉ូលា"បិទបាំងមនុស្សមួយក្តាប់តូច ឧទាហរណ៍គាត់បានផ្តល់មធ្យោបាយឱ្យមនុស្សមួយក្តាប់តូចដូចជាបោះតង់ ជួយផ្តល់អង្ករដាំបាយ ដើម្បីជួយតវ៉ារំដោះអ្នកទោសដែលជាចោរប្លន់ជាដើម។

-ចំពោះករណីរំលោភសេពសន្ថវៈហើយសម្លាប់ជាដើមនោះ ស្ថាប័នជំនាញត្រូវការប្រមូលរកភស្តុតាងគ្រប់គាន់ ហេតុនេះត្រូវទាមទារឱ្យមានពេទ្យជំនាញខាងកោសល្យវិច័យ ដើម្បីឱ្យស្របតាមនីតិវិធី ប៉ុន្តែបញ្ហាលំបាកត្រង់ថា ស្រុកខ្លះនៅឆ្ងាយដាច់ស្រយ៉ាល យើងពិបាករកអ្នកជំនាញដើម្បីពិនិត្យឱ្យបានត្រឹមត្រូវ។

-បញ្ហាការពាក់ព័ន្ធនឹងការទប់ស្កាត់ក្មេងទំនើង ដែលខាងអង្គការក្រៅរដ្ឋាភិបាល បានលើកឡើងអំពីការឃុំខ្លួនលើសនីតិវិធី លោកស្នងការបានទទួលស្គាល់ថាអាចដូច្នេះមែន ព្រោះលោកយល់ថា ក្មេងទំនើងនេះទាល់តែប្រើធមិក្តៅខ្លះត្រជាក់ខ្លះព្រោះពួកគាត់ លែងស្តាប់អាណាព្យាបាល ដូច្នេះការខិតខំទប់ស្កាត់ក្មេងទំនើងបែបនេះរហូតដល់ថ្ងៃបុណ្យភ្ជុំបិណ្ឌឆ្នាំនេះ ពុំមានក្មេងទំនើងបែបនេះបង្កបញ្ហាក្នុងខេត្តយើងនោះទេ។

យោងតាមរបៀបវារៈ ពេលវេលាជាបន្តគឺពិភាក្សាតាមក្រុម់លទ្ធផល នៃការពិភាក្សាតាមក្រុមមានភ្ជាប់ជាឧបសម្ព័ន្ធ នៃរបាយការណ៍សិក្ខាសាលា។

បន្ទាប់ពីការស្រាយបំភ្លឺនូវបញ្ហាមួយចំនួន ដែលបានលើកឡើងក្នុងបទបង្ហាញរបស់ក្រុមពិភាក្សា លោកប្រធានតុលាការ លោកព្រះរាជអាជ្ញារង រួមទាំងលោកអភិបាលរងខេត្ត ទទួលបន្ទុកការងារការងារសិទ្ធិមនុស្សផងនោះ ឯកឧត្តមប្រធានអង្គសិក្ខាសាលាបាន ធ្វើការបូកសរុបលទ្ធផលនៃការពិភាក្សា និងបានធ្វើការវាយតម្លៃខ្ពស់ចំពោះការចូលរួមមតិដ៏ផុសផុលរបស់អង្គសិក្ខាសាលារយៈពេល ពីរថ្ងៃកន្លងមកនេះ។ ហើយឯកឧត្តមក៏បានកោតសរសើរផងដែរថា សិក្ខាសាលានៅខេត្តបន្ទាយមានជ័យនេះ ពិតជាមានសារៈសំខាន់ណាស់ និងទទួលបាននូវលទ្ធផលគួរជាទីមោទនៈ។

មុននឹងបញ្ចប់ឯកឧត្តមប្រធានបានថ្លែងអំណរអរគុណចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា មន្ត្រីមកពីមន្ទីរជុំវិញខេត្ត ព្រមទាំងអង្គការសង្គមស៊ីវិលទាំងអស់ ដែលបានចំណាយពេលវេលាចូលរួមក្នុងអង្គសិក្ខាសាលារយៈពេលពីរថ្ងៃ និងសូមប្រសិទ្ធិពរទាំងប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ជូនដល់អង្គសិក្ខាសាលាទាំងមូល។

អង្គសិក្ខាសាលាបានចប់សព្វគ្រប់នៅវេលាម៉ោងដប់ពីរថ្ងៃត្រង់នាថ្ងៃបន្ទាប់។

*រាជធានីភ្នំពេញ ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩*

បានឃើញ និងឯកភាព

អគ្គលេខាធិការរង | អ្នកធ្វើរបាយការណ៍

សួង លាងហៃ | ស៊ុន សិរីវុធ

ការបែងចែកក្រុមពិភាក្សាទៅលើប្រធានបទ: បញ្ហាការប្រឈមចំពោះសិទ្ធិទទួលបានយុត្តិធម៌ពីតុលាការ (ការប្រឈម ចំពោះការផ្តល់សេវា និងទទួលសេវាពីតុលាការ)ការផ្តល់ជាមតិយោបល់

ក្រុមទី១ ៖ មេឃុំចៅសង្កាត់

I.បញ្ហាប្រឈម

១-ការដាក់ពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋក្រីក្រ តុលាការចាត់ការយឺតយ៉ាវ ករណីខ្លះបាត់ពាក្យបណ្តឹងក្នុងរឿងក្តីនិមួយៗ ច្រើនមានអ្នកជួញក្តី ។

២-រាល់ដីកាកោះ សេចក្តីសម្រេចផ្សេងៗខ្លះ ម្ចាស់បំណុលតែងឱ្យកូនបំណុលផ្ទាល់

-ប្រជាពលរដ្ឋក្រីក្រ ពុំមានថវិកាជួលមេធាវី

-ប្រជាពលរដ្ឋពុំដែលបានទទួលការផ្សព្វផ្សាយអំពីច្បាប់ និងសេវាផ្សេងៗពីស្ថាប័នតុលាការ ។

II.ការផ្តល់មតិ និងសំណូមពរ

១-ករណីអង្កេតរឿងក្តីនីមួយៗសុំឱ្យតុលាការស៊ើបអង្កេតឱ្យបានច្បាស់លាស់។

២-ស្នើឱ្យតុលាការពេលចេញសេចក្តីសម្រេចណាមួយ មេត្តាជួយពន្យល់ដល់ភាគីបំណុលឱ្យបានយល់ពីសិទ្ធិរបស់ខ្លួន ។

៣-រាល់ពេលសម្របសម្រួលរឿងក្រៅប្រព័ន្ធតុលាការនៅថ្នាក់ឃុំ (រដ្ឋប្បវេណី ) ដែលភាគីទាំងពីរព្រមព្រៀងរួចហើយ។

៤-ក្រោយមកមានអ្នកញុះញង់ភាគីណាមួយប្តឹងមកតុលាការ សូមឱ្យតុលាការមេត្តាយកកិច្ចព្រមព្រៀងរបស់ថ្នាក់ឃុំធ្វើ ជាទុន និងពិចារណាផងចុះ។

៥-សុំអោយមានការបណ្តុះបណ្តាលច្បាប់ដល់ក្រុមប្រឹក្សាឃុំ-សង្កាត់។

ក្រុមទី២ ៖ អភិបាលស្រុក និងអភិបាលរង

I.បញ្ហាប្រឈម ៖

ការទទួលសេវាពីតុលាការជាមួយគូវិវាទ ឬប្រជាពលរដ្ឋពុំទាន់ល្អប្រសើរ

១-ការផ្តល់ព័ត៌មាន ឬផ្ញើរដីកាកោះ ពុំមានភ្នាក់ងាររបស់តុលាការជូនដល់ដៃអ្នកទទួលនៅឡើយ ច្រើនផ្ញើតាមរយៈរថយន្ត តាមឃុំ ឬផ្សេងៗ។

២-ក្រឡាបញ្ជីខ្លះពុំគោរពពេលវេលា។

៣-មន្ត្រីតុលាការខ្លះ ចុះទៅគោះជនរងគ្រោះ ឬអ្នកពាក់ព័ន្ធដល់លំនៅដ្ឋាន ទាមទារកម្រៃផ្សេងៗ និងអះអាងថាខ្លួនជួយ សម្រួល។

៤-មានការធ្វើអន្តរាគមន៍ពីថ្នាក់លើ គ្រប់រូបភាពអោយជួយដល់ភាគីជាបក្សពួក ឬសាច់ញាតិរបស់ខ្លួនផ្ទុយ នឹងសិទ្ធិស្រប ច្បាប់របស់ប្រជាពលរដ្ឋ។

៥-ករណីខ្លះមាន ស.ជ.ណ ចេញផ្ទុយពីសាលក្រមតុលាការតើមូលដ្ឋានគួរយកករណីណាមួយមកអនុវត្ត?

៦-ប្រជាពលរដ្ឋខ្វះថវិកាជូលមេធាវីការពារក្តី ព្រោះសេវាមេធាវីខ្ពស់។

II.ការផ្តល់មតិ និងសំណូមពរ

១- សុំឱ្យស្ថាប័នតុលាការមានភ្នាក់ងារ ជូនដំណឹងដល់ជនរងគ្រោះ ឬគូវិវាទឱ្យដល់ដៃ ឬដល់លំនៅដ្ឋាន

២- សូមអោយមន្រ្តីតុលាការគោរពពេលវេលា ដែលជនរងត្រូវបានណាត់ជួប

៣- ក្នុងករណីដែលមន្រ្តី ឬភ្នាក់ងារតុលាការចុះជួបគូវិវាទ កុំឱ្យទាមទារកម្រៃ និងសុំឱ្យមានលិខិតបង្គាប់ការច្បាស់លាស់

៤- សុំឱ្យតុលាការកាត់ក្តីតាមអំណាចឯករាជ្យរបស់ខ្លួន កុំយកអន្តរាគមន៍ពីអ្នកដ៏ទៃ។

៥- សុំឱ្យមានមេធាវីការពារក្តីដល់ជនរងគ្រោះក្រីក្រ ហើយមានទីស្នាក់ការនៅជិតតុលាការងាយស្រួលដល់ជនរងគ្រោះ

ក្រុមទី៣ ៖ អធិការប៉ូលិស

I.បញ្ហាប្រឈមប្រជាពលរដ្ឋ ៖

-ការយល់ដឹងពីច្បាប់នៅមានកំរិត

-ការផ្សព្វផ្សាយច្បាប់របស់តុលាការ (ក្រមនីតិវិធីទាំងពីរ )

-ការផ្តល់សេវាព័ត៌មានអំពីនីតិវិធី ក្នុងរឿងក្តីពីតុលាការទៅជនរងគ្រោះ ឬសាក្សី ឬជនសង្ស័យនៅមានកំរិត។

-ភាពក្រីក្ររបស់ប្រជាពលរដ្ឋគ្មានអ្នករំពឹង (សម្រាប់ប្រជាពលរដ្ឋនៅតំបន់ដាច់ស្រយ៉ាល)

-សេវារដ្ឋបាលរបស់តុលាការនៅមានកំរិត

II.បញ្ហាប្រឈមរបស់សមត្ថកិច្ច:

-ខ្វះការចូលរួមពីស្ថាប័នពាក់ព័ន្ធ (បច្ចេកទេស )សម្រាប់ផ្នែកសុខាភិបាល (ករណីមនុស្សឃាត ចាំបាច់ត្រូវការពេទ្យ កោសល្យវិច័យពីខាងសុខាភិបាល។

- គ្មានកញ្ចប់ថវិកាបម្រើឱ្យសមត្ថកិច្ចប្រតិបត្តិការ

-ទម្រង់បែបបទរបស់តុលាការមិនទាន់ផ្តល់អោយ សូមឱ្យមានទម្រង់បែបបទសរសេរកំណត់ហេតុសួរបំភ្លឺ សួរចម្លើយរបស់ មន្ត្រីនគរបាលយុត្តិធម៌ (តម្រូវឱ្យមានការស៊ើបអង្កេតបទល្មើសដល់កន្លែងទើបឈានដល់ការរែកមុខសញ្ញា ) ។

-ការទទួលដីការបស់តុលាការ:

-ដីកាចូលខ្លួន (មានដីកាបញ្ឈប់ និងអនុវត្ត )

-ដីកានាំខ្លួន (មានដីកាបញ្ឈប់ និងអនុវត្ត )

-ដីកាចាប់ខ្លួន (មានដីកាបញ្ឈប់ និងអនុវត្ត )

III. ការផ្តល់មតិ និងសំណូមពរ ៖

១-សូមស្នើកែទម្រង់អំពីបទលួច និងអំពីបទប្លន់ (ឧ. លួចមាន់មានគ្នាពីរនាក់ចោទពីបទប្លន់ រីឯរួចទ្រព្យសម្បត្តិមានទឹក ប្រាក់១០០០០ ដុល្លារ ឬក៏ច្រើនជាងចោទពីបទលួច ? )។

២-ស្នើសុំថវិការលើមធ្យោបាយបញ្ជូនដីការបស់តុលាការ។

ក្រុមទី៤០: កងរាជអាវុធហត្ថស្រុក ខេត្ត

I.បញ្ហាប្រឈមៈ

១-ការផ្តល់សេវាពីតុលាការ ផ្តល់ឱ្យកងរាជអាវុធហត្ថ

២-ការទទួលដីកា និងការបញ្ជូនឯកសារទៅតាមមូលដានឆ្ងាយ

៣-ការស៊ើបអង្កេត និងមធ្យោបាយ

៤-ការប្រឈមរបស់ប្រជាពលរដ្ឋជាមួយតុលាការ

-ការដោះលែងជនសង្ស័យសំអាងលើមូលហេតុច្បាប់ -ភស្តុតាងមិនគ្រប់គ្រាន់។

ក្រុមទី៥ៈ ផ្នែកឯកជន និងអង្គការមិនមែនរដ្ឋាភិបាល

I.បញ្ហាប្រឈមៈ

១- ភាពយឺតយ៉ាវក្នុងចំណាត់ការរឿងក្តី (ឯកជន)

២-ការស៊ើបអង្កេតរបស់តុលាការនៅមានកំរិត (រឿងព្រហ្មទណ្ឌ និងរឿងរដ្ឋប្បវេណី)

៣-ខ្វះការសហការពីមន្ត្រីស្ថាប័នជំនាញ

៤-និទណ្ឌភាព

៥-នៅមានការទារប្រាក់កម្រៃសេវាបន្ថែមពីជនរងគ្រោះ ដើមបណ្តឹង (ក្រៅពីប្រាក់ពន្ធ និងប្រាក់ក្រៅពន្ធ)

៦-បណ្តឹងព្រហ្មទណ្ឌនៅតែមានការទាមទារលើកម្រៃសេវាផ្សេងៗ

៧-នីតិវិធីនៃយន្តការដោះស្រាយវិវាទដីធ្លីរបស់តុលាការ និងគណៈកម្មាការសុរិយោដី នៅមាន ត្រួតស៊ីគ្នា

៨-ការបម្រើសេវាកម្មផ្នែករដ្ឋបាលតុលាការក្នុងប្រព័ន្ធតុលាការមិនទាន់បង្ហាញពីគណនេយ្យភាព និងតម្លាភាព

៩- បុរេសន្ធត់

II. ការផ្តល់មតិ និងសំណូមពរ ៖

១- គួរតែយកចិត្តទុកដាក់ក្នុងការចំណាត់ការរឿងក្តីអោយបានឆាប់។

២-គួរតែមានការស៊ើបអង្កេត និងសាកសួរពីព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ។

៣-គួរតែមានការចូលរួមដោយសកម្មពីមន្ត្រីជំនាញ។

៤-គួរតែអនុវត្តទៅតាមច្បាប់ ។

៥-គួរតែមានប្រព័ន្ធត្រួតពិនិត្យតាមដានលើការផ្តល់សេវាកម្ម។

៦-បណ្តឹងព្រហ្មទណ្ឌមិនត្រូវទាមទារលើកម្រៃសេវាផ្សេងៗ ។

៧-គួរតែបង្វិលសំណុំរឿងដែលមិនមែនជាកាតព្វកិច្ចរបស់តុលាការជូនទៅស្ថាប័នពាក់ព័ន្ធដោះស្រាយ(ជំនាញ)។

៨-រាល់ការបម្រើសេវាកម្មផ្នែករដ្ឋបាលត្រូវមានវិក្ក័យប័ត្រ ។

៩-គួរតែកែប្រែនូវបុរេសន្ធត់

ក្រុមទី៦ ៖មន្ទីរជុំវិញខេត្ត

I.បញ្ហាប្រឈមៈ ចំពោះសិទ្ធិទទួលបានយុត្តិធម៌ពីតុលាការ

១-ធនធានមនុស្ស (ចំណេះដឹងជំនាញ )។

២-សមត្ថកិច្ចជំនាញ

៣-លិខិតបទដានគតិយុត្ត

៤-ការរំលោភលើសមត្ថកិច្ច

៥-ការរំលោភអំណាច

៦-កិច្ចសហការ និងមន្ត្រីនគរបាលយុត្តិធម៌

ក្រុមទី៧ ៖ស្ថាប័នតុលាការ អយ្យាការ និងពន្ធនាគារ

I.បញ្ហាប្រឈមក្នុងបែបបទរដ្ឋបាល

១- ការផ្តល់សេវា:

-កង្វះធនធានមនុស្ស (ថៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី សម្ភារៈ ថវិកា )

-ការគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋក្នុងមូលដាន

-កិច្ចសហការពីអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ

-ស្ថានភាពភូមិសាស្ត្រ ហេដ្ឋារចនាសម្ព័ន្ធ

-ជីវភាព (ការមិនយកចិត្តទុកដាក់ក្នុងរឿងក្តីរបស់ខ្លួន )

២-ការសម្រេចក្តី:

-ឯករាជ្យភាពរបស់ថៅក្រម

-រំលោភសមត្ថកិច្ច

-អន្តរាគមន៍

-ការមិនសហការអនុវត្ត

-ស្ថានភាពនយោបាយ

-មធ្យោបាយបង្ហាញភស្តុតាងនៅមានកំរិត:

-កោសល្យវិច្ច័យ (កង្វះធនធាន សម្ភារៈ ថវិកា )

-ជំនាញផ្សេងៗ (ការបញ្ជាក់ពីស្នាមមេដៃ និងសារធាតុញៀន )

-សាក្សីមិនសហការ

-ឯកសារ

II. ការផ្តល់មតិ និងសំណូមពរ ៖ គ្មាន